ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
ស្តីពី
ករណីឥដ្ឋមានទីរុសកូវីដ-១៩ ថ្មី ចំនួន ០៤នាក់ និងមិនមានអ្នកជាសះស្បើយ
នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖

គិតត្រឹមម៉ោង ០៧:០០ព្រឹកថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជាមាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **៣០៤**នាក់ (ស្មើនឹង ៩០,៧៥% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៦១នាក់ និងបុរស ២៤៣នាក់។
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **៣៣៥**នាក់ (ស្ត្រី ៧៦នាក់ និងបុរស ២៥៩នាក់)។
- អ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ ចំនួន **២៦នាក់** (ស្រី ១២នាក់ និងបុរស ១៤នាក់)។
- អ្នកសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ ចំនួន **០៥នាក់** (ស្ត្រី ០៣នាក់ និងបុរស ០២នាក់)។

២. ករណីឥដ្ឋមានទីរុសកូវីដ-១៩ ៖ ចំនួន ០៤នាក់ ដែលជាអ្នកពាក់ព័ន្ធទៅនឹង "ព្រឹត្តិការណ៍សហគមន៍ ២៨ធ្នូ"

-បុរសជនជាតិខ្មែរអាយុ ៣៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅបូរីលឹម ឈាងហាក់ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ជាបុគ្គលិកនៅហាងលក់កុំព្យូទ័រឈ្មោះ ឌីមកំព្យូទ័រ ផ្លូវព្រះសីហនុ រាជធានីភ្នំពេញ ដែលត្រូវជាបងថ្លៃជីដូនមួយរបស់បុរសអាយុ ២៣ឆ្នាំ ដែលបានរកឃើញមានវីរុសកូវីដ-១៩ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ កំពុងតែសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

-ស្ត្រីជនជាតិខ្មែរអាយុ ៣២ឆ្នាំ ជាភរិយាបុរសអាយុ ៣៩ឆ្នាំខាងលើ មានអាសយដ្ឋានស្នាក់នៅបូរី លឹម ឈាងហាក់ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលត្រូវជាបងប្អូនជីដូនមួយបុរសអាយុ ២៣ឆ្នាំ ដែលបានរកឃើញវីរុសកូវីដ-១៩ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០។

-កុមារជនជាតិខ្មែរអាយុ ០៣ឆ្នាំ ត្រូវជាកូនប្រុស បុរសអាយុ ៣៩ឆ្នាំ និងស្ត្រីអាយុ ៣២ឆ្នាំ ខាងលើ មានអាសយដ្ឋានស្នាក់នៅបូរី លឹម ឈាងហាក់ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលត្រូវជាក្មួយប្រុសបុរសអាយុ ២៣ឆ្នាំ ដែលបានរកឃើញវីរុសកូវីដ-១៩ នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០២០។

- បុរសជនជាតិខ្មែរអាយុ ២២ឆ្នាំ មានអាសយដ្ឋាននៅសង្កាត់ទាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាបុគ្គលិកហាង Pedro ផ្លូវព្រះសីហនុ ជាអ្នកប៉ះបាល់ជាមួយអ្នកជំងឺជាស្ត្រីអាយុ ២១ឆ្នាំ

ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសង្កាត់ចំបើង ខណ្ឌ(ប្រអប់)ភ្នំពេញ ទូរស័ព្ទ-ទូរសារ: ០២៣-៨៨៤ ០៤០/ ០២៣ ៨៨៤ ០០៩

ដែលបានចូលទៅហាងនោះដែរ។

លទ្ធផលធ្វើតេស្តវត្ថុសំណាករបស់បុគ្គលទាំង ៨នាក់ខាងលើនេះ ផ្តល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ គឺ ជួបមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្នអ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។

៣. មិនមានករណីជាសះស្បើយ ៖ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០

៤. លទ្ធផលធ្វើតេស្តអ្នកប៉ះពាល់ក្នុង "ក្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា"

នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ វត្ថុសំណាកដែលនៅសល់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ចំនួន ៥៦នាក់ ឬក បន្ថែមចំនួនវត្ថុសំណាកទទួលបានបន្ថែមនៅថ្ងៃដដែលពីខេត្ត និងរាជធានីភ្នំពេញ សរុបមានចំនួន ១,០២៧ នាក់ ត្រូវបានធ្វើវិភាគដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា គឺមានលទ្ធផល ជួបមានវីរុសកូវីដ-១៩ ថ្មី ចំនួន ០៥នាក់ (ដែលជាអ្នកជំងឺខាងលើនេះ)។ ដោយឡែកមាននៅសល់វត្ថុសំណាកចំនួន ៧៥សំណាកផ្សេងទៀតដែលត្រូវវិភាគបន្តនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០។

គិតពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ ក្រសួងសុខាភិបាល បានធ្វើតេស្តអ្នកប៉ះពាល់សរុបទាំងអស់បានចំនួន ៥,៧៥៣នាក់ ដែលនៅក្នុងចំនួននេះ មានអ្នកជួបមានវីរុសកូវីដ-១៩ ថ្មី សរុបចំនួន ២៣នាក់ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

៥. ការក្រើនរំលឹករបស់ក្រសួងសុខាភិបាល

ដោយសង្កេតឃើញថា មានការកើនឡើងនូវអ្នកជំងឺកូវីដ-១៩ ដែលមានការចម្លងបន្តគ្នាពីកន្លែងមួយទៅកន្លែងមួយ ហើយការអុករកស្រាវជ្រាវកំពុងតែត្រូវបានធ្វើយ៉ាងសកម្មនោះ ក្រសួង សូមអំពាវនាវឲ្យគ្រប់អ្នកប៉ះពាល់ក្នុង "ក្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា" ទាំងអស់ ជាពិសេសអ្នកដែលប៉ះពាល់ជាមួយអ្នកជំងឺដែលធ្វើការនៅធនាគារកាថេ (ផ្លូវសម្តេចប៉ាន) និងធនាគារចិន (អាគារកាណាឌីយ៉ា ផ្លូវព្រះមុនីវង្ស) ក្នុងរាជធានីភ្នំពេញ តម្រូវឲ្យធ្វើចត្តាឡីស័កនៅផ្ទះ ឬនៅសណ្ឋាគារ ឬនៅតាមមណ្ឌលចត្តាឡីស័កនៅតាមខេត្ត ឲ្យបានគ្រប់ចំនួន ១៤ថ្ងៃ និងអនុវត្តន៍វិធានការការពារខ្លួនកុំឲ្យចម្លងទៅអ្នកដទៃ ឲ្យបានត្រឹមត្រូវជាទីបំផុត ទៅតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងរបស់ក្រសួងសុខាភិបាល ហើយកុំដើរចេញក្រៅផ្ទះ ឬចេញព័មណ្ឌលចត្តាឡីស័ក ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនេះឲ្យសោះ ដើម្បីទប់ស្កាត់ការចម្លងវីរុសដ៏កាចសាហាវនេះ ពីម្នាក់ទៅម្នាក់ និងកុំឲ្យមានការរាតត្បាតនៅក្នុងសហគមន៍។ អាជ្ញាធរជាក់ក្រោមជាតិ មានបន្ទុកទទួលខុសត្រូវលើការចាត់ចែង គ្រប់គ្រង និងតាមដានការធ្វើចត្តាឡីស័កនេះ ដោយបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនក្នុងការរក្សាការពារខ្លួនកុំឲ្យមានការឆ្លងវីរុសកូវីដ-១៩ មកខ្លួនឯង ទៅអ្នកដទៃ និងនៅក្នុងសហគមន៍ ដើម្បីសុខភាពផ្ទាល់ខ្លួនលោកអ្នក ក្រុមគ្រួសារលោកអ្នក និងសហគមន៍ បានចៀសផុតនូវការឆ្លងជំងឺដ៏កាចសាហាវនេះ។

សម្រាប់បងប្អូនប្រជាពលរដ្ឋទូទៅ សូមបន្តការរស់នៅធម្មតាតាមបែបគន្លងថ្មី ដោយពាក់ម៉ាស់ (ក្នុងករណីចាំបាច់) ជាពិសេសនៅក្នុងកាលទេសៈនេះ សូមកុំដើរចេញក្រៅផ្ទះ បើមិនចាំបាច់ តែបើអាក់ខានមិនបាន ពេលចេញដើរ ត្រូវពាក់ម៉ាស់ជាប់ជានិច្ច ត្រូវលាងសម្អាតដៃជាមួយសាប៊ូ និងទឹកស្អាត ឬជាមួយអាល់កុល ឬទឹកដែលសម្រាប់លាងដៃ ឲ្យបានញឹកញាប់ កុំយកដៃដែលមិនបានលាងសម្អាត មកប៉ះផ្នែកមុខមាត់របស់ខ្លួន និងត្រូវរក្សាសុវត្ថិភាពសង្គម (សូមកុំឲ្យមានការជួបជុំគ្នាកុះករច្រើនលើសពី២០នាក់ បើមានការជួប

ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចចៃន ឧត្តម(២៨ស) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: ០២៣ ៨៨៥ ២៣៦/ ០២៣ ៨៨៥ ៩០៤

គ្នាក្នុងចំនួនតិចជាង២០នាក់ ត្រូវអនុវត្តន៍វិធានការសុខាភិបាលត្រឹមត្រូវដូចបានណែនាំជារៀយៗ) និងរក្សាគម្លាតសុវត្ថិភាពបុគ្គលឲ្យលើសពីមួយម៉ែត្រកន្លះឡើងទៅជាចាំបាច់។ ពេលនេះ ជាដំណាក់កាលសំខាន់បំផុត ដែលប្រជាជនទាំងអស់ សូមចូលរួមសាមគ្គីគ្នាក្នុងការអនុវត្តន៍វិធានការសុខាភិបាលដ៏មានសារៈសំខាន់នេះ ដើម្បីទប់ស្កាត់ការចម្លងរាលដាលក្នុងសហគមន៍ក្នុងទ្រង់ទ្រាយធំ និងដើម្បីបងប្អូនអាចបន្តការរស់នៅជាធម្មតាតាមបែបគន្លងថ្មី។ សូមកុំភ្លេចវីរុសកូវីដ-១៩ ព្រោះវីរុសកូវីដ-១៩ មិនទាន់ទៅណាឆ្ងាយពីយើងនៅឡើយទេ ហើយវីរុសដ៏កាចសាហាវនេះ កំមិនភ្លេចយើងដែរ បើយើងធ្វេសប្រហែស វីរុសនេះ នឹងវិលុកសរីរាង្គកាយយើងហើយ។ ដូច្នេះ មានតែវិធីការពារខ្លួនឲ្យបានខ្ជាប់ខ្ជួនតាមការណែនាំខាងលើនេះទេ ដែលអាចជួយទប់ស្កាត់បានជាអតិបរិមានូវការចម្លងពីបុគ្គលទៅបុគ្គល ពីបុគ្គលទៅក្រុមគ្រួសារខ្លួន និងពីបុគ្គលចម្លងរាតត្បាតក្នុងសហគមន៍ទ្រង់ទ្រាយធំ។

ប្រសិនបើមានបងប្អូនប្រជាពលរដ្ឋ មានបញ្ហាសុខភាពដែលសង្ស័យជាជំងឺកូវីដ-១៩ សូមអាយការណ៍ទៅក្រុមគ្រូពេទ្យជាបន្ទាន់ ដោយសូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទខាងក្រោមនេះ។

ម្យ៉ាងវិញទៀត សូមអ្នកប៉ះពាល់ទៅនឹង "ព្រឹត្តិការណ៍សហគមន៍ ២៨ធ្នូ" ទាំងអស់ អញ្ជើញទៅ**ធ្វើតេស្តជាលើកទី២ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០** ខាងមុខនេះ ដែលក្រសួងសុខាភិបាល នឹងរៀបចំទីតាំងយកវត្ថុសំណាក នៅបរិវេណក្រសួងនហាថ្មៃ ពហុកីឡាដ្ឋានជាតិអូឡាំពិច រាជធានីភ្នំពេញ និងទៅតាមមន្ទីរសុខាភិបាល ខេត្ត (ដែលទទួលខុសត្រូវក្នុងការរៀបចំទីកន្លែងនៅពេលនោះ សម្រាប់អ្នកពាក់ព័ន្ធនៅតាមខេត្ត)។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញការកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៨ ឬ ០១២ ៨៨៨ ៥៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសុក្រ ៨រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០

ទីស្តីការក្រសួងសុខាភិបាល ជីឡូតិ៍លេខ ៨០ ថ្នល់សាមព័ន្ធចំរើន ខណ្ឌឫស្សីកែវ ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៥៧០ / ៨៨៥ ៥០៩